**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**
**សម្រាប់ទិវានៃការត្រាស់ហៅនៅព្រះសហគមន៍សន្តីម៉ារីញញឹម**
**ចំការទៀន ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២០**

# ចូរតាំងចិត្តក្លាហានឡើង! ខ្ញុំទេតើ

| |
|---|
| **ដំណឹងល្អ៖ ម៉ាថាយ ១៤,២២-៣៦** |
| ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ ចូរតាំងចិត្តក្លាហានឡើង ខ្ញុំទេតើ កុំខ្លាចអី!។ មថ ១៤,២៧ |

បងប្អូនជាទីស្រឡាញ់!

អម្បាញ់មិញយើងបានស្តាប់ព្រះគម្ពីរដំណឹងល្អ ដែលណែនាំឲ្យយើងឃើញក្រុមគ្រីស្តទូតកំពុងឆ្លងសមុទ្រ នៅពេលនោះមានខ្យល់ព្យុះធ្វើឲ្យគេភ័យ។ គេឃើញព្រះយេស៊ូ ដែលដើរលើសមុទ្រ ណែនាំឲ្យគេភ្ញាក់ដូចមានខ្មោចលង។ ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា "**ចូរតាំងចិត្តក្លាហានឡើង! ខ្ញុំទេតើ!**" ក្រោយមកព្រះយេស៊ូបានហៅលោកសិលាឲ្យមកជួបព្រះអង្គ។

យុវជនជាទីស្រឡាញ់!

នៅក្នុងទិវានៃការត្រាស់ហៅ សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានសរសេរសារលិខិតជូនដល់យុវជនទាំងអស់នៅក្នុងពិភពលោកទាំងមូល ដើម្បីឲ្យយើងជាយុវជនយុវនារីដែលកំពុងគិតអំពីអនាគត គិតអំពីតម្លៃនៃជីវិត អំពីដំណើរនៃជីវិតរបស់យើង "**តើនៅថ្ងៃអនាគត យើងធ្វើអ្វីខ្លះ? តើយើងរៀបចំខ្លួនដើម្បីឆ្លើយតបទៅព្រះជាម្ចាស់យ៉ាងដូចម្តេច?**"។ តាមពិតសម្តេចប៉ាបមាន៤ចំណុចដែលព្រះអង្គចង់ជំរុញយើង ដោយយល់ថានៅពេលយើងចង់ធ្វើដំណើរជាមួយព្រះជាម្ចាស់ ព្រះជាម្ចាស់គង់នៅជាមួយយើងគ្រប់ពេលវេលា៖

**ទីមួយ ត្រូវមានចិត្តអរព្រះគុណព្រះជាម្ចាស់** ចិត្តដែលបង្ហាញសេចក្តីស្រឡាញ់ដែលយើងមានចំពោះព្រះជាម្ចាស់។ តាមពិត ពេលយើងឃើញរបៀបដែលគ្រីស្តទូតឆ្លងសមុទ្រជាមួយព្រះយេស៊ូ ដូចជាជីវិតរបស់យើង។ ជីវិតរបស់យើងត្រូវតែឆ្លង ពីកន្លែងមួយទៅកន្លែងមួយទៀត និងពេលយើងសម្រេចចិត្តទៅអនាគតយើងត្រូវការគិត។ **អនាគតយើងទៅដល់ណា? ទៅកន្លែងណា?** ជួនកាលយើងដើរដូចជាវង្វេងតិចៗ ជួនកាលមានខ្យល់ដែលណែនាំឲ្យយើងចង់ដួល។ ជួនកាលមានអារម្មណ៍ថាមានខ្មោចលងយើង ជួនកាលយើងភ័យខ្លាច។ ប៉ុន្តែ នៅពេលនោះយើងឮព្រះយេស៊ូដែលមានព្រះបន្ទូលថា "**ខ្ញុំទេតើ! កុំខ្លាចអី! សូមមានចិត្តក្លាហានឡើង**"។ ដូច្នេះ

ថ្ងៃនេះឲ្យយើងសូមអរព្រះគុណព្រះជាម្ចាស់ ដោយសារយើងដឹងថាព្រះយេស៊ូគង់នៅជាមួយយើង និងព្រះអង្គមិនលះបង់ចោលយើង។

**ទីពីរ ឲ្យយើងមានសេចក្តីក្លាហាន** ដូចព្រះយេស៊ូមានព្រះបន្ទូល ពេលលោកសិលាចង់ដើរតាមព្រះអង្គ ពេលនោះលោកសិលាកំពុងលង់ទឹក ប៉ុន្តែព្រះយេស៊ូនៅទីនោះហើយចាប់ដៃគាត់ឲ្យគាត់អាចធ្វើដំណើរតទៅទៀតជាមួយព្រះយេស៊ូ "**កុំខ្លាចអី! សូមមានសេចក្តីក្លាហាន**"។ យើងដឹងថា ព្រះជាម្ចាស់មានគម្រោងការសម្រាប់យើង ព្រះជាម្ចាស់ធ្វើដំណើរជាមួយយើងជានិច្ច អត់ដែលលះបង់ចោលយើង ព្រះអង្គចាប់ដៃយើងដើម្បីនៅជាមួយយើងជានិច្ច។ ប៉ុន្តែ ជួនកាលយើងភ័យខ្លាចរឿងមួយទៀត ជួនកាលយើងមានអារម្មណ៍ថា៖ ខ្ញុំបម្រើព្រះសហគមន៍អស់មួយជីវិត ជាលោកឪពុក ជាបងប្រុសបងស្រី... ណែនាំឲ្យខ្ញុំអស់កម្លាំងមែនទែន។ ពេលខ្ញុំឃើញលោកឪពុករត់ទៅនេះទៅនោះ ពេលខ្ញុំឃើញបងស្រីធ្វើការងារច្រើនៗ ជួនកាលខ្ញុំគិតថាខ្ញុំធ្វើមិនបានទេ ប្រហែលខ្ញុំអស់កម្លាំងមែនទែន។ ប៉ុន្តែ សូមយុវជនយុវនារីជាទីស្រឡាញ់!ពិចារណាបន្តិច ប្រសិនបើយើងមានកសិករនៅក្នុងចម្ការរបស់ព្រះជាម្ចាស់យ៉ាងច្រើន នោះយើងនឹងអាចចែកការងារស្រួលជាង។ យើងមានបូជាចារ្យមួយចំនួនធំ យើងមានបងស្រីមួយចំនួនធំ យើងអាចចែកការងារបានស្រួល ទៅតាមភូមិនីមួយៗដែលព្រះសហគមន៍មានជីវិត តាមកន្លែងដែលយើងធ្លាប់ទៅ និងទៅកន្លែងដែលយើងអត់ដែលទៅដល់។ ដូច្នេះ ភាពអស់កម្លាំងរបស់យើងប្រហែលអត់មានទេ ដោយដឹងថាទោះបីអស់កម្លាំងក៏ដោយ ក៏ព្រះយេស៊ូនៅជាមួយយើងដែរ។

**ទីបី ជាពេលវេលាអរព្រះគុណព្រះជាម្ចាស់** កោតសរសើរ លើកតម្កើងព្រះជាម្ចាស់ដូចព្រះនាងម៉ារី។ យើងចូលនៅក្នុងខែរបស់ព្រះនាងម៉ារី នៅពេលគាត់ទទួលដំណឹងល្អធ្វើជាម្តាយរបស់ព្រះជាម្ចាស់ ព្រះនាងម៉ារីរត់ទៅជួបជាមួយយាយអេលីសាប៉ែត ដើម្បីសួរសុខទុក្ខផង និងជាពិសេសដើម្បីបង្ហាញអំណរសប្បាយដែលគាត់មាននៅក្នុងចិត្ត និងព្រះនាងម៉ារីចាប់ផ្តើមច្រៀងកោតសរសើរព្រះជាម្ចាស់ ដែលបានជ្រើសរើសគាត់ ដែលបានស្រឡាញ់គាត់ ដែលបានធ្វើដំណើរជាមួយគាត់។

**ទីបួន ជាពេលវេលាដើម្បីដូចព្រះនាងម៉ារី** យើងទទួលការត្រាស់ហៅរបស់ព្រះជាម្ចាស់សម្រាប់ជីវិតយើង។ **តើយើងអាចបម្រើព្រះសហគមន៍យ៉ាងដូចម្តេច? តើយើងអាចបម្រើបងប្អូនឯទៀតៗយ៉ាងដូចម្តេច? តើយើងអាចបម្រើសង្គមរបស់យើងដូចម្តេច?** សព្វថ្ងៃ យើងឃើញកូវីដ១៩ណែនាំឲ្យយើងភ័យខ្លាច ប៉ុន្តែក៏ណែនាំឲ្យយើងគិតពិចារណាដែរ ដោយសារយើងទៅសាលាមិនបាន យើងទៅរៀនធម្មតាមិនបាន យើងទៅដើរលេងជាមួយមិត្តភ័ក្តរបស់យើងមិនបានដូចពីមុន យើងបង្កើតទំនាក់ទំនងជិតស្និទ្ធដូចពីមុនមិនបាន។ ណែនាំឲ្យយើងគិតពិចារណា **តើមានអ្វីខ្លះ**

**សំខាន់បំផុតនៅក្នុងជីវិតរបស់យើង?** "ចម្លើយ ប្រហែលព្រះជាម្ចាស់" ព្រះជាម្ចាស់កំពុងត្រាស់ហៅប្អូនៗជាយុវជនយុវនារី ដើម្បីគិតពិចារណា **តើខ្ញុំអាចធ្វើអ្វីខ្លះនៅក្នុងជីវិតខ្ញុំ ទៅលើព្រះសហគមន៍និងទៅលើសង្គម?** លើសពីនេះទៀត **តើខ្ញុំអាចធ្វើជីវិតទាំងស្រុងរបស់ខ្ញុំទៅលើព្រះជាម្ចាស់ ដើម្បីណែនាំមនុស្សលោក ណែនាំបងប្អូនទាំងអស់ ជាពិសេសបងប្អូននៅប្រទេសកម្ពុជាដើម្បីឲ្យគេអាចស្គាល់ព្រះយេស៊ូ ដែលជាព្រះសង្គ្រោះដែលមានជីវិតអស់កល្បជានិច្ច និងដែលណែនាំឲ្យយើងចូលនៅក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់?**

យុវជនយុវនារីជាទីស្រឡាញ់! ជាពេលវេលាដើម្បីឆ្លើយតបដូចព្រះនាងម៉ារី "ខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់" និងដើម្បីចែករំលែកអំណរសប្បាយដែលយើងមាន ជាមួយបងប្អូនឯទៀតៗ ពិតមែនព្រះជាម្ចាស់បានជ្រើសរើសខ្ញុំ ពិតមែនព្រះជាម្ចាស់ណែនាំឲ្យខ្ញុំមានកម្លាំងកាយកម្លាំងចិត្ត ដើម្បីបម្រើ ដើម្បីស្រឡាញ់ និងដើម្បីអធិដ្ឋាន។ សូមជូនពរ និងសូមបន្តអធិដ្ឋានយ៉ាងស្ងៀមស្ងាត់ ដើម្បីភ្ជាប់ជាមួយព្រះយេស៊ូ ដែលជាជីវិត ដែលជាផ្លូវ ដែលជាសេចក្តីពិត។ អាម៉ែន៕